**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ០១.១៩០/០៧ គ.ជ.ប.អគ្គ.ពស**

ភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៧

# គ.ជ.ប លុបឈ្មោះបេក្ខជនចំនួន ២៦រូប ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយ ចំនួន ៣

នៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៧ គ.ជ.ប បានសម្រេចលុបឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោត ចំនួន ២៦រូប ចេញពីបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនយោបាយចំនួន ៣ នៅសង្កាត់ចំនួន ៥ ក្នុងក្រុងភ្នំពេញ តាមការស្នើសុំរបស់បេក្ខជនផ្ទាល់ ។

បេក្ខជនទាំង ២៦រូប ដែល គ.ជ.ប បានលុបចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយ ក្នុងនោះមានចំនួន ១៩រូប បានលុបចេញពីបញ្ជីបេក្ខជននៃគណបក្សសម រង្ស៊ី នៅសង្កាត់ចំនួន ៤ គឺសង្កាត់ច្បារអំពៅទី១ ចំនួន ១រូប សង្កាត់បឹងកេងកងទី១ ចំនួន ៨រូប សង្កាត់ទន្លេបាសាក់ចំនួន ១រូប និងសង្កាត់ច្រាំងចំរេះទី១ ចំនួន ៩រូប ហើយចំនួន ៦រូប បានលុបចេញពីបញ្ជីបេក្ខជននៃគណបក្សរណសិរ្សសង្គមជាតិនិយម នៅសង្កាត់ច្បារអំពៅទី១ និង ចំនួន ១រូប បានលុបចេញពីបញ្ជីបេក្ខជននៃគណបក្សនរោត្តម រណឫទ្ធិ នៅសង្កាត់ចាក់អង្រែលើ ។

ការលុបឈ្មោះបេក្ខជននៅក្រោយការបិទផ្សាយបញ្ជីបេក្ខជនដំបូងនេះ មិនធ្វើឱ្យប៉ះពាល់ដល់បញ្ជីបេក្ខជននៃសាមីគណបក្សនយោបាយឡើយ ។